# ចែករំលែកចំណេះដឹងនៃបទពិសោធន៍
# SHARE EXPERIENCE KNOWLEDGE

**ការវិភាគកំសាន្ត**
**(Informal Analysis)**

ប្រធានបទសម្រាប់ចែករំលែក (Subject to be shared) : អ្នកនេសាទពីរគ្រួសារបោះតង់ក្បែរគ្នា

កាលបរិច្ឆេទនៃការចែករំលែក (Date of this sharing) : ២១ មេសា ២០១២

វិភាគកំសាន្ត ដោយ (Informal analysis shared by) : លោក សៀង ប៊ូហឿង

## ១. សេចក្ដីផ្ដើម (Introduction)




ពេលរាត្រីស្ងាត់មុនចូលគេង នៅក្នុងតង់នៃគ្រួសារទី១ ឪពុកកំពុងរៀបរាប់ពីបទពិសោធន៍របស់គាត់ ក៏ដូចជាការផ្ដល់ដំបូន្មានដល់កូនៗរបស់គាត់ ។ ខណៈពេលដែលកូនៗរបស់គាត់កំពុងត្រងត្រាប់ស្ដាប់យ៉ាងយកចិត្តទុកដាក់ អ្នកនេសាទដែលនៅក្នុងតង់ក្បែរគ្នានៃគ្រួសារទី២ បានស្ដាប់លឺហើយរអ៊ូរទាំថា អួតដល់កហើយ អាអួតអើយ!

**២. ការយល់ដឹង (Knowledge)**

តាមខ្លឹមសារនៃសាច់រឿងខាងលើ យើងឃើញថា ពាក្យសម្ដីតែមួយ គ្រាន់តែថាអ្នកស្ដាប់មានពីរប្រភេទ ឬពីរក្រុម : ម្ខាងជាកូនៗរបស់អ្នកដែលកំពុងនិយាយ និងម្ខាងទៀតជាអ្នកនេសាទម្នាក់ទៀត។ កូនៗរបស់គាត់យល់ឃើញថាឪពុកជាទីគោរពរបស់ពួកគេ ស្រលាញ់ពួកគេ ដូច្នេះរាល់ការរៀបរាប់របស់ឪពុកពួកគេ ត្រូវបានពួកគេចាត់ទុកថាជាការចែករំលែកបទពិសោធន៍ និងជាការផ្ដល់ដំបូន្មាន ជាហេតុធ្វើអោយពួកគេត្រងត្រាប់ស្ដាប់យ៉ាងយកចិត្តទុកដាក់។ តែដោយឡែកចំពោះអ្នកនេសាទដែលបោះតង់ក្បែរ និងដែលបានលឺដូចគ្នាទៅនឹងកូនៗទាំងនោះ បែរជាចាត់ទុកថានេះជាការអួតទៅវិញ អាចដោយសារតែគាត់បានដឹងអស់ហើយនូវអ្វីដែលគាត់លឺ ឬក៏ដោយសារគាត់មិនសូវចូលចិត្តអ្នកដែលកំពុងនិយាយនោះ ឬមួយដោយសារគាត់យល់ថាការនិយាយនោះហួសពីការពិតដែលគាត់បានដឹង។

**៣. ការផ្ដល់អនុសាសន៍ (Recommendation)**

ខ្ញុំបាទសូមធ្វើការផ្ដល់ជាគំនិតយោបល់យ៉ាងខ្លីថា បើទោះបីជាបុគ្គលដែលនិយាយនោះ កំពុងចែករំលែកបទពិសោធន៍ ឬកំពុងផ្ដល់ដំបូន្មាន ឬកំពុងអួត យើងគប្បីគួរកុំខ្វល់ គឺគ្រាន់តែគិតក្នុងន័យវិជ្ជមាន ដោយចម្រាញ់យកអ្វីដែលល្អទៅបានហើយ។ ផ្ទុយទៅវិញបើអ្នកជាអ្នកកំពុងនិយាយវិញ ពេលបានលឺ ឬដឹងថាអ្នកស្ដាប់គិតថាអ្នកកំពុងតែអួត ចូរកុំខឹងពីព្រោះនេះជារឿងធម្មតាទេ ហើយវាអាស្រ័យទៅលើតែអ្នកស្ដាប់យល់ឃើញតែប៉ុណ្ណេះ។